ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ ២៦០

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

លេខៈ ..២៤៣...... អ.យ.គ

ផ្នែកព្រហ្មទណ្ឌស៊ើបសួរ
ចុះថ្ងៃទី..០៤......ខែ..តុលា...ឆ្នាំ..២០២១......
បញ្ជូនទៅ..[illegible]......

## ដីកាសន្និដ្ឋានស្ថាពរ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២២៤ អ.យ.គ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ លិខិតជូនព័ត៌មានអំពីការបញ្ចប់ការស៊ើបសួរលេខ ២៣៣៥ ច.ព្រទ(ច)/២១ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ ដីកាបញ្ជូនរឿងទៅពិនិត្យលេខ ១២១០ ច.ព្រទ(ច) /២១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា ÷**

១-ឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា ៤២ឆ្នាំ រស់នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ (អត្តសញ្ញាណមិនគ្រប់គ្រាន់)

២-ឈ្មោះ រី ភេទប្រុស អាយុប្រហែលជា ៣២ឆ្នាំ រស់នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រើប្រាស់លេខទូរស័ព្ទ ០៨៨ ២០ ៤៤៤ ២៨។ (អត្តសញ្ញាណមិនគ្រប់គ្រាន់)

៣-ឈ្មោះ [redacted] មុំ ហៅ មុំ ភេទស្រី កើតថ្ងៃទី ០៩.០៦.១៩៦៨ សញ្ជាតិខ្មែរ មុខរបររមេផ្ទះ ទីកន្លែងកំណើតភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម អាសយដ្ឋានភូមិបន្ទាយ [redacted]

[redacted]



Scanned with CamScanner

រមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ប្តីឈ្មោះ[redacted] ឪពុកឈ្មោះ [redacted]ម្តាយឈ្មោះ [redacted] ។ (គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ ១៩៨៣ សញ្ជាតិ ខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កសិករ កម្រិតវប្បធម៌ថ្នាក់ទី០៦ថ្មី ,ទីកន្លែងកំណើតជិរុំថាវដាង ប្រទេសថៃ,អាសយដ្ឋាន [redacted] ថ្មពួក ខេត្តបន្ទាយមានជ័យ,ប្រពន្ធឈ្មោះ [redacted] កូនចំនួន ០៥ នាក់ ឪពុកឈ្មោះ [redacted](រ) ,ម្តាយឈ្មោះ [redacted] (រ) ,ជា នីតិជន ទោសពីមុន គ្មាន ។ (មានខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

**ឃើញថា៖** កាលពីថ្ងៃទី ០៨ ខែមីនា ២០២១ កម្លាំងនគរបាលនៃប៉ុស្តិ៍រដ្ឋបាលគោករមៀត បានធ្វើប្រតិបត្តិការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំនុចភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដោយឃាត់ខ្លួនបាន ជនសង្ស័យចំនួន ០១ នាក់ឈ្មោះ [redacted] ឡា។ ឆ្លងកាត់ការសាកសួរនៅដំណាក់កាលសមត្ថកិច្ច ឈ្មោះ[redacted] ឡា បានឆ្លើយសារភាពថា ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ធី ,ឈ្មោះ រី ដែលប្រើប្រាស់លេខទូរស័ព្ទ [redacted] និងឈ្មោះ មុំ ដើម្បីយកមកប្រើប្រាស់ និងរំលែកលក់បន្ត។

**បានឃើញ៖**

-ចម្លើយរបស់សាក្សីឈ្មោះ[redacted]រ៉េត ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ចំពោះករណីដែលពាក់ព័ន្ធនឹងឈ្មោះ [redacted] ឡា ខ្លួនសូមរៀបរាប់ជូនថា ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ម៉ោងប្រហែលជា១១ថ្ងៃត្រង់ មានអ្នកប្រកបរបរបោកអ៊ុតឈ្មោះ [redacted] ហួរ ភេទប្រុស អាយុ៣៦ឆ្នាំ បានមករាយការណ៍ថា គាត់ជាអ្នកដើរប្រមូលខោអាវតាមផ្ទះមកបោកអ៊ុត ហើយពេលដែលយកខោអាវរបស់ឈ្មោះ [redacted] ឡា គឺប្រពន្ធរបស់[redacted]ឡា យកចេញពីផ្ទះមកឱ្យគាត់ គាត់ក៏បានយកមកដល់ផ្ទះគាត់ ហើយបានរៀបចំបោកគក់ដោយរើយកចេញពីថង់មកបានពាក់កណ្តាល ស្រាប់តែឃើញថង់ខ្មៅមួយ គាត់មានការឆ្ងល់ ទើបគាត់យកដាក់មកលើតម្របពាង ហើយបានស្រាយមើល ឃើញម្សៅក្រាមសថ្លា និងថង់ច្រកតូចៗ សង្ស័យថាជាគ្រឿងញៀន ក៏ជិះម៉ូតូមករាយការណ៍ នៅនឹងទីស្នាក់ការប៉ុស្តិ៍។ ខ្លួនក៏បានឱ្យកំលាំងរបស់ខ្លួនម្នាក់ឈ្មោះ ខាត់ សុឃី ជាមន្ត្រីនគរបាលប៉ុស្តិ៍ ទៅជាមួយនឹងអ្នកបោកខោអាវដើម្បីពិនិត្យ ឃើញដូចការរាយការណ៍ គឺពិតជាថ្នាំញៀនប្រភេទម៉ាទឹកកក ហើយក៏ចាប់ដកយកវត្ថុតាងមកប៉ុស្តិ៍ តែម្តង។ បន្ទាប់ពីបានឃើញវត្ថុដែលចាប់មក



[redacted]

Scanned with CamScanner

ហើយ ខ្លួនក៏បានរាយការណ៍ទៅអធិការស្រុកហើយបានរាយការណ៍ផ្ទាល់ទៅឧត្តមសេនីយ៍ស្នងការខេត្តផ្ទាល់ផងដែរ និងទទួលបានបទបញ្ជាពីឧត្តមសេនីយ៍ស្នងការឱ្យទៅនាំខ្លួនឈ្មោះ [redacted] ឡា ពីផ្ទះ មកប៉ុស្តិ៍ ហើយប្រគល់ឱ្យខាងជំនាញ របស់អធិការស្រុកថ្មពួក និងមានលោកស្នងការឈ្មោះ [redacted]ដត ដែលមានវត្តមាននៅនឹងប៉ុស្តិ៍ ធ្វើការសាកសួរ ហើយខាងខ្លួនចូលរួមស្តាប់ និងចូលរួមស៊ីញ៉េលើកំណត់ហេតុ។ ពាក់ព័ន្ធនឹងដីកាកោះរបស់ឈ្មោះ [redacted] ហួរ ដែលតុលាការបានធ្វើការកោះហៅ ខាងប៉ុស្តិ៍ក៏បានទទួលដែរ និងបានឱ្យកំលាំងប៉ុស្តិ៍ដែលមានឈ្មោះ [redacted] ញូន ធ្វើការបញ្ជូនទៅដល់ផ្ទះគាត់ដែរ តែឃើញនៅតែប្រពន្ធគាត់ឈ្មោះ [redacted] លៃល្ងួរ កំពុងតែប្រកបរបរអាជីវកម្មបោកអ៊ុត ចំណែកឈ្មោះ [redacted] ហួរ មិននៅទេ ហើយពេលកំលាំងប៉ុស្តិ៍យើងទាក់ទងតាមទូរស័ព្ទទៅឈ្មោះ [redacted] ហួរ បែរជាឈ្មោះ [redacted]ហួរ បញ្ជាក់ថា បានទៅនៅស្រុកវិញបាត់ហើយតាំងពីពេលដែលមានរឿងហេតុកើតឡើង ព្រោះបារម្ភពីសុវត្ថិភាព។ ប៉ុន្តែមុនមកឆ្លើយបំភ្លឺនេះមួយថ្ងៃឈ្មោះ [redacted] ហួរ ក៏បានទាក់ទងមកខ្លួន ប្រាប់ថា គាត់មិនមានលទ្ធភាព ឡើងមកបភ្លឺទេ។ ឈ្មោះ [redacted] ហួរ មានលេខទូរស័ព្ទ ០៨៨ [redacted]។ ឈ្មោះ [redacted] ហួរ ជាមនុស្សយ៉ាងម៉េចខ្លួនមិនដឹងទេ ព្រោះខ្លួនទើបធ្វើការក្នុងតួនាទីជាមេប៉ុស្តិ៍បានរយៈពេលមួយឆ្នាំជាងប៉ុណ្ណោះ ហើយឈ្មោះ [redacted] ហួរ ក៏ជាអ្នកចំណូលថ្មីដែរ ដែលគាត់មកនៅប្រហែលជាបីឆ្នាំហើយ។ ចំពោះឈ្មោះ [redacted] ឡា វិញ ខ្លួនសូមបញ្ជាក់ថា ក្នុងរយៈពេលខ្លួនកាន់តួនាទីនៅនឹងប៉ុស្តិ៍ មួយឆ្នាំជាង ហើយប្រហែលជាប្រាំទៅប្រាំមួយខែចុងក្រោយនេះ ក៏បានស៊ើប និងលឺព័ត៌មានថាឈ្មោះ [redacted] ឡា មានការពាក់ព័ន្ធនឹងការប្រើប្រាស់ និងចែកចាយដែរ តាមការជំនាញស៊ើបអង្កេត។ ខ្លួនសូមបញ្ជាក់ឡើងវិញថា បន្ទាប់ពីខ្លួនធ្វើការទាក់ទងបញ្ជាក់ជាមួយខាងមន្ត្រីជំនាញស្រុកហើយ និងមន្ត្រីប៉ុស្តិ៍រួចមកខាងខ្លួនមិនដែលបានទទួលបញ្ជារណា ឱ្យធ្វើការស្រាវជ្រាវអត្តសញ្ញាណរបស់ឈ្មោះ [redacted]ឡា នេះទេ តែអាចមានការស្ទួរនាំតាមទូរស័ព្ទអំពីអត្តសញ្ញាណរបស់ឈ្មោះ [redacted]ឡា ទើបធ្វើឱ្យមានការយល់ច្រលំ។ ហើយការបញ្ជាក់ថា មានការចាប់បានអ្នកប្រើប្រាស់ឆ្លើយថា បានពីឈ្មោះ [redacted] ឡា និងអ្នកប្រើប្រាស់បានបញ្ជូនទៅមណ្ឌលដែរ នោះ មិនមានទេ តែមានការបញ្ជាក់ផ្ទាល់មាត់ មិនមានឯកសារបញ្ជាក់ឡើយ។ ចំពោះការដាក់បន្ទុកទៅលើឈ្មោះ[redacted]ឡា បន្ថែមក្រៅពីសំណុំរឿងខ្លួនពុំមានអ្វីបន្ថែមទៀតទេ។ ឈ្មោះ [redacted] ឡា ជាកូនចុងរបស់មេឃុំគោករមៀត។ ហើយឈ្មោះ [redacted] ឡា មានម្តាយឈ្មោះ វ៉ាត់ ជាអ្នករកស៊ីលានដំឡូង ហើយមានចំការដំឡូងខ្លួនឯង ហើយឈ្មោះ[redacted] ឡា និងប្រពន្ធ ជួយធ្វើការងារឱ្យម្តាយ ព្រោះម្តាយមានចំការច្រើន។

✓-ចម្លើយរបស់សាក្សីឈ្មោះ [redacted] សំរេច ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ខ្លួនជាអ្នកដែលទទួលបញ្ជារពីមេប៉ុស្តិ៍ ដើម្បីចុះទៅហៅឈ្មោះ [redacted] ឡា ពីផ្ទះរបស់គាត់មក ប៉ុស្តិ៍ និងពេលទៅនោះគឺខ្លួនទៅបីនាក់ មានខ្លួន និងឈ្មោះ [redacted]សុឃី និងឈ្មោះ[redacted] ញូន បន្ទាប់ពីនាំឈ្មោះ [redacted]ឡា មកដល់ប៉ុស្តិ៍ហើយ ភ្លាម មេប៉ុស្តិ៍បញ្ជាឱ្យទៅនៅយាមផ្ទះរបស់ឈ្មោះ [redacted] ឡា វិញភ្លាម ហើយពួកខ្លួនក៏ទៅ តែនៅយាមក្រៅផ្ទះ គ្រាន់តែក្នុងបរិវេណរបង រហូតកន្លះម៉ោងក្រោយទើបជំនាញពីខេត្តដល់ ដោយមានស្នងការរងម្នាក់ជាអ្នកដឹកនាំ មិនមានខាងអយ្យការទេ ហើយខាងជំនាញបានស្នើសុំឆែកឆេរផ្ទះ ដោយមានការយល់ព្រមរបស់បងប្អូនរបស់ឈ្មោះ [redacted] ឡា និងពេលឆែកឆេររកអ្វីមិនឃើញទេ បានខ្លួនផ្ទាល់ ធ្វើការផ្សៀវផ្ទៀងជុំវិញផ្ទះ



[redacted]

ក៏បានឃើញថ្នាំមួយគ្រាប់ទើបធ្វើការចាប់ដកហូតមកធ្វើជាភស្តុតាង។ ហើយពេលមកដល់ប៉ុស្តិ៍ក៏មិនបានធ្វើអ្វីបន្ថែមទៀតដែរ គឺខាងជំនាញគេអ្នកធ្វើទាំងអស់។

✓ -ចម្លើយរបស់សាក្សីឈ្មោះ [redacted] ហួរ ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ច ថា៖ នៅថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០២១ វេលាម៉ោងប្រហែល ១០ ព្រឹក ខ្លួនបានជិះម៉ូតូដើរយកខោអាវបោកអ៊ុតដូចសព្វដង នៅតាមភូមិ ដោយខ្លួនបានទៅយកខោអាវនៅផ្ទះ ចៃម្នាក់នៅភូមិវល្លិ៍ប្រេង (ក្រចករណ្តើក) ពុំស្គាល់ឈ្មោះ ដឹងត្រឹមថាគាត់ជាកូនប្រសាររបស់ចៃវ៉ាត់ ម្ចាស់លានដំឡូងភូមិវល្លិ៍ប្រេង ហើយចៃម្ចាស់ខោអាវគាត់បានប្រមូលខោអាវដាក់ចូលក្នុងថង់ខ្មៅធំមួយលើកមកឱ្យខ្លួន ខ្លួនក៏បានដឹកខោអាវនោះមកផ្ទះ ហើយមិនបានដើរយកខោអាកន្លែងផ្សេងទៀតទេ ខ្លួនក៏រៀបចំរើខោអាវនោះចេញពីថង់ខ្មៅធំនោះ ដើម្បីដាក់ចូលម៉ាស៊ីនបោក ខ្លួនបានយកខោអាវដាក់ ចូលម៉ាស៊ីនអស់ប្រហែលពាក់កណ្តាល ខ្លួនក៏បម្រុងរើយកខោអាវដែលនៅសល់ក្នុងថង់ក៏ស្រាប់តែឃើញមានថង់ដៃពណ៌ខ្មៅមួយនៅក្រោមខោអាវក្នុងថង់ខ្មៅធំដាក់ខោអាវនោះ ខ្លួនចង់ដឹងថាថង់នោះមានអ្វីក៏យកដាក់លើគ្របពាងស្រាយមើលក៏ឃើញមានម្សៅពណ៌ ស ច្រកថង់ពណ៌ ស មួយដុំនិងមានថង់ពណ៌ ស តូចៗជាច្រើន ហើយពេលឃើញដូច្នេះ ខ្លួនមានការសង្ស័យថា ជាគ្រឿងញៀនក៏មករាយការណ៍ជូនសមត្ថកិច្ចឱ្យទៅមើល ហើយពេលសមត្ថកិច្ចទៅដល់ គាត់ក៏បានពិនិត្យ ម្សៅ ស ក្នុងថង់នោះ រួចពួកគាត់ក៏យកប៉ុស្តិ៍និងហៅខ្លួនមកសាកសួរ រឿងហេតុនៅប៉ុស្តិ៍។ ពេលខ្លួនអង្គុយបានមួយសន្ទុះ ប្រពន្ធខ្លួនណាបានទូរស័ព្ទមកសួរនាំខ្លួនថា មានចៃម្ចាស់ខោអាវ ថង់ខ្មៅធំនោះ មកសួររកថាមានឃើញកញ្ចប់ឥវ៉ាន់ក្នុងថង់ខោអាវហ្នឹងអត់ ហើយខ្លួនបាននិយាយប្រាប់ប្រពន្ធ ខ្លួនថា មិនឃើញទេ ហើយខ្លួនក៏បានបិទទូរស័ព្ទទៅ ព្រោះខ្លួនកំពុងរាយការណ៍ជូនសមត្ថកិច្ចខ្លាចបែកការណ៍។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] លៃហួន ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ខ្លួនមានប្តីមុនឈ្មោះ [redacted] សុធាវី បានលែងលះគ្នាតាំងពីកូនខ្លួនទីពីរមិនទាន់បានបីខែ តែបច្ចុប្បន្នកូនទីពីរខ្លួនអាយុ១១ឆ្នាំ តែពួកវាទៅរស់នៅជាមួយមីងមា នៅស្រុកកំណើត បានបួនឆ្នាំហើយគិតដល់ពេលនេះ ចំណែកខ្លួនរស់នៅម្នាក់ឯង លើដីដែលម្តាយខ្លួនបន្សល់ឱ្យ ដោយប្រកបរបរបោកអ៊ុត និងធ្វើចំការ។ ចំពោះប្តីខ្លួនឈ្មោះ ញ៉ាញ់ នេះ គឺស្គាល់គ្នាតាមទូរស័ព្ទ បានប្រហែលកន្លះខែ ក៏យកគ្នាជាប្តីប្រពន្ធតែម្តងទៅ ដោយសារតែគាត់អង្វរសុំរស់នៅជាមួយ តែពេលរស់នៅជាមួយគ្នា មើលទៅគាត់ដូចជាមនុស្សឡប់ៗ ម៉េចមិនដឹង និយាយមិនសូវដឹងអ្វីដូច្នេះមិនត្រូវគ្នាទេ ហើយតាំងពីថ្ងៃដែល ថាប៉ូលីសចុះទៅដល់ផ្ទះនោះមក គឺបាត់គាត់មិនដឹងទៅណាទេ សូម្បីតែថ្ងៃដែលប៉ូលីសចុះនោះ ក៏ខ្លួនមិនដឹងរឿងអីផង ព្រោះខ្លួនមិនបាននៅផ្ទះទេ គឺខ្លួនទៅនៅចំការប្រហែលជាមួយខែជាងហើយ ព្រោះឈ្លោះគ្នាជាមួយគាត់ រហូតទាល់តែមានអ្នកជិតខាងគេប្រាប់ថាផ្ទះចំហរទ្វារចោល ហើយពីថ្ងៃមានប៉ូលីសចុះមក មិនដឹងមានរឿងអី ទើបខ្លួនចេញពីចំការមកផ្ទះដោយដល់ផ្ទះម៉ោងប្រហែជាប្រាំពីរយប់ ឃើញផ្ទះចំហរទ្វាចោល មិនឃើញប្តីខ្លួនទេ តាំងពីពេលនោះមកមិនឃើញប្តីខ្លួននោះទេ ទោះបីទូរស័ព្ទក៏គេមិនចូលដែរ។ ប្តីខ្លួនឈ្មោះ ញ៉ាញ់ នេះ មិនដឹងគាត់មានស្រុកកំណើតនៅទីណាទេ ព្រោះពេលសួរម្តងថានៅពោធិ៍សាត់ និងម្តងថានៅស្មោង ខ្លួនក៏ឈប់សួរទៅ ព្រោះរាល់ពេលដែលនិយាយគ្នាគឺឈ្លោះគ្នារហូត។



[redacted]

Scanned with CamScanner

ខ្លួនសូមបញ្ជាក់ពួកខ្លួនមិនបានរៀបការទេ គឺស្រឡាញ់គ្នា ក៏មកនៅជុំគ្នាតែម្តងទៅ មិនមានអ្នកណាដឹងលឺ ក្រៅពីអ្នកជិតខាងទេ សូម្បីម៉ែឪបងប្អូនរបស់គាត់ក៏មិនដែលឃើញមក ឬ ជួបខ្លួន បានស្គាល់គ្នាដែរ។ ខ្លួននឹងប្តីខ្លួនគឺបានគ្នាជាប្តីប្រពន្ធប្រហែលជាប្រាំបីខែហើយ តែសាច់ដែលនៅជាមួយគ្នាបានប្រហែលជាពីរខែប៉ុណ្ណោះ សូម្បីតែបានគ្នាភ្លាម គឺរស់នៅជាមួយគ្នាបានតែកន្លះខែប៉ុណ្ណោះ គាត់ក៏ខឹង ហើយវេចខោអាវទៅបាត់ បានយូរក៏មកវិញ សរុបទៅគាត់រត់ចោលខ្លួនប្រហែលជាដប់ពីរដងហើយ ១រឿងមិនមានអ្វីធំដុំទេ គឺរឿងប្រាប់ឱ្យធ្វើការងារប៉ុណ្ណោះឯង។ ប្តីខ្លួនគាត់មានពាក់ព័ន្ធនឹងរឿងគ្រឿងញៀនឬអត់ខ្លួនមិនដឹងទេ តែគាត់ធ្លាប់ខឹងកំរោល វាយពាងរបស់របរដែរ ប៉ុន្តែមិនដែលវាយខ្លួនទេ។ ចំពោះឈ្មោះ [redacted] ឡា ខ្លួនស្គាល់ និងដឹងថាគាត់ជាមនុស្សក្នុងភូមិឃុំ ហើយក៏មិនដែលលឺថាគាតើមានការពាក់ព័ន្ធនឹងគ្រឿងនោះទេ តែគាត់មានការពាក់ព័ន្ធឬអត់ខ្លួនមិនដឹងទេ។ ចំពោះរឿងគ្រឿងញៀន កន្លែងបោកអ៊ុត ដែលប្តីខ្លួនថាជារបស់ឈ្មោះ [redacted] ឡា នេះ ខ្លួនមិនបានដឹងទេ ព្រោះខ្លួនមិនបាននៅផ្ទះ តែសំដីរបស់ប្តីខ្លួននិយាយមកខ្លួនមិនសូវជឿជាក់ទេ ព្រោះធ្លាប់កុហក់ខ្លួនសូម្បីតែកន្លែងកំណើតម្តងទីនេះម្តងទីនោះ។ ចំពោះចម្លើយរបស់ប្តីខ្លួនដែលថា " ហៅខ្លួនមកសាកសួររឿងហេតុនៅនឹងប៉ុស្តិ៍ អង្គុយបានមួយសន្ទុះ ប្រពន្ធខ្លួនបានតេតាមទូរស័ព្ទមកសួរនាំខ្លួនថា មានចែម្ចាស់ខោអាវចង់ខ្មៅធំនោះមកសួររកថាមានឃើញកញ្ចប់ឥវ៉ាន់ក្នុថង់ខោអាវនិងអត់" នេះ គឺខ្លួនជាប្រពន្ធគាត់មិនបានតេរកគាត់ទេ ព្រោះខ្លួនមិនបាននៅផ្ទះផង ហើយក៏មិនបានដឹងរឿងទៀត ដោយមានអ្នកជិតខាង អាចបញ្ជាក់ថា ខ្លួនមិនបានដឹងរឿង ហើយខ្លួននិងផ្តល់ភស្តុតាងដើម្បីបញ្ជាក់រឿងនេះ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៉ាន់ ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ក្នុងនាមជាសាក្សីខ្លួនសូមរៀបរាប់ជូនតុលាការថា ខ្លួនជាអ្នកជិតខាងជាមួយឈ្មោះ លៃសួន ដែលមានប្តីឈ្មោះ ញ៉ាញ់ ដោយរស់នៅក្នុងភូមិជាមួយគ្នា តែផ្ទះឃ្លាតគ្នាប្រហែលជាហាសិបម៉ែត្រប៉ុណ្ណោះ និងរស់នៅរាប់អានគ្នា សូម្បីតែពេលឈ្មោះ លៃសួន ណ្ណោះគ្នាជាមួយប្តី គឺបានទៅរស់នៅ ដេក និងចំការរបស់ខ្លួន ជួយដាំដំណាំនៅនឹងចំការរបស់ខ្លួន ហើយយកផលរៀងខ្លួន ព្រោះខ្លួនជាស្ត្រីមេម៉ាយ ពីមុនឈ្មោះ លៃសួន ក៏ជាស្ត្រីមេម៉ាយដែរ។ ហើយនៅថ្ងៃដែលផ្ទះវាមានរឿង ពីដំបូងក៏ខ្លួនមិនបានដឹងដែរ តែថ្ងៃនោះខ្លួនត្រូវចេញពីចំការមកផ្ទះ ម៉ោងជិតប្រាំពីរយប់ហើយ ដើម្បីយកអង្ករ និងពេលមកនោះ បានលឺថា ផ្ទះរបស់ឈ្មោះ លៃសួន មានបញ្ហា តែមិនដឹងបញ្ហាអីទេ និងលឺថាប្តីវារត់បាត់ នៅសល់តែផ្ទះចំហទ្វារចោល ទើបខ្លួនទៅមើលឃើញផ្ទះវាចំហទ្វារចោលមែន ខ្លួនក៏ត្រឡប់ទៅចំការប្រាប់ឈ្មោះ លៃសួន ហើយបានដឹកឈ្មោះ លៃសួន មកមើលផ្ទះវាទៀតផង ដោយឈ្មោះ លៃសួន ចូលផ្ទះរកប្តីមិនឃើញមែន ហើយក៏បានបិទទ្វារ រួចនាំគ្នាត្រឡប់ទៅចំការវិញ។ ខ្លួនក៏សូមបញ្ជាក់ផងដែរថា ឈ្មោះ លៃ សួន ណ្ណោះគ្នាជាមួយប្តីវាឈ្មោះ ញ៉ាញ់ ហើយវាក៏បានទៅរស់នៅចំការជាមួយខ្លួន ដេកជាមួយខ្លួនរយៈពេលប្រហែលមួយខែហើយរហូតដល់ថ្ងៃដែលមានបញ្ហាខាងលើនេះ។ ចំពោះឈ្មោះ ញ៉ាញ់ ជាមនុស្សយ៉ាម៉េចខ្លួនមិនច្បាស់ទេ តែពេលនិយាយគ្នាជាមួយគាត់ និងមើលការនិយាយស្តីរបស់គាត់ជាមួយប្រពន្ធ គឺគាត់និយាយដូចមិនសូវច្បាស់លាស់ទេ ជួនខឹង ជួនអត់ ជួនកាលនិយាយស្តាប់គ្នាមិនបានក៏មានដែរ ឆ្កួតៗ ហើយខ្លួនក៏មិនសូវនិយាយជាមួយគាត់ដែរ។



[redacted]

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ថាវ៉ាត់ ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ខ្លួនត្រូវជាម្ដាយបង្កើតរបស់ឈ្មោះ [redacted]ឡា តែពេលកើតមក ខ្លួនមានជីវភាពក្រលំបាក ក៏បានឱ្យវាទៅគេយកទៅចិញ្ចឹម ហើយក្រោយមកអ្នកចិញ្ចឹមវាបានស្លាប់អស់ ទើបពេលមានគ្រួសារ ជាប្រពន្ធកូនហើយ ក៏ត្រឡប់មករស់នៅក្នុងភូមិឃុំជាមួយខ្លួនទៀត តែប្រពន្ធវាមានជំងឺបេះដូង ដូចមានបញ្ជាក់របស់គ្លីនិកសិរីសោភ័ណ ១ និងមានបញ្ហាពាក់ព័ន្ធនឹងការគិតច្រើន ចង់វង្វេងវង្វាន់ផង និយាយសួរដឹងអីទេ ដូចមានលិខិតពេទ្យ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១។ ចំពោះកូនខ្លួនឈ្មោះ [redacted] ឡា គឺវាធ្វើតែស្រែចំការប៉ុណ្ណោះ ហើយខ្លួនក៏ឱ្យលុយកាក់វាចាយខ្លះដែរ ដោយមិនឱ្យប្ដីក្រោយខ្លួនដឹងទេ ព្រោះប្ដីខ្លួនគាត់ជាឪពុកចុង មិនសូវចូលចិត្តកូនដើម មានចិត្តចង្អៀតដែរ ខ្លួនក៏មិនដែលលឺឬឃើញថាកូនខ្លួនឈ្មោះ [redacted] ឡា ប្រព្រឹត្តបទល្មើស រកស៊ីគ្រឿងញៀនអ្វីនោះទេ។ ដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់កូនខ្លួន ខាងអាជ្ញាធរភូមិ ក៏បានធ្វើលិខិតបញ្ជាក់មួយ មកផងដែរ ដែលខ្លួននឹងស្នើសុំដាក់បញ្ចូលជាភស្តុតាងផងដែរ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភា ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ពីមុនខ្លួនមានផ្ទះនៅជិតជាមួយបងប្អូនរបស់ឈ្មោះ [redacted] ឡា តែពេលខ្លួនបានប្ដី ខ្លួនក៏ទៅនៅក្បែរផ្សារវិញ តែនៅចេញចូលទៅលេងផ្ទះបងប្អូនរបស់ឈ្មោះ [redacted] ឡា ដដែល ហើយក៏លេងចំការ ដែលឈ្មោះ [redacted] ឡា ស្នាក់នៅផងដែរ ដូចជាមួយទៅពីរសប្ដាហ៍បានទៅម្ដង ដើម្បីបេះស្វាយ ញ៉ាំ។ ក្នុងនាមខ្លួនដែលធ្លាប់ទៅលេង និងស្គាល់គ្នាជាមួយឈ្មោះ [redacted] ឡា មិនដែលលឺថាគាត់លក់ថ្នាំញៀនទេ សូម្បីប្រើប្រាស់ក៏ខ្លួនមិនដែលលឺដែរ ហើយពេលខ្លួនទៅលេងក៏មិនដែលឃើញមានអ្នកប្លែកមុខឬក្មេងៗទៅរកឈ្មោះ [redacted]ឡា ឬ ចេញចូលផ្ទះរបស់ឈ្មោះ [redacted] ឡា ដែរ បើមានគឺមានតែអ្នកកាប់ដំឡូងប៉ុណ្ណោះ។ ចម្លើយខ្លួនមានតែប៉ុណ្ណឹងឯង ហើយក៏ជាចម្លើយពិតដែរ ខ្លួនហ៊ានទទួលខុសត្រូវចំពោះចម្លើយរបស់ខ្លួន។ ខ្លួនរស់នៅក៏មិនដែលលឺថាអ្នកណាលក់ ឬ អ្នកណាប្រើប្រាស់ថ្នាំញៀននោះដែរ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted]ង៉ា ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ ថា៖ ខ្លួនជាអ្នកជិតរបស់ឈ្មោះ [redacted] ឡា ឃ្លាតគ្នាប្រហែលជាពីរទៅបីផ្ទះប៉ុណ្ណោះ ហើយខ្លួន និងប្ដី ក៏ជាអ្នកស៊ីឈ្នួលកាប់ដំឡូងឱ្យឈ្មោះ [redacted] ឡា ដែរ។ ខ្លួនរស់នៅជិតផ្ទះរបស់ឈ្មោះ [redacted]ឡា មិនដែលឃើញនៅនឹងផ្ទះគាត់មានសកម្មភាពអ្វី ដែលមនុស្សប្លែក ឬ ក្មេង ចេញចូល រកទិញគ្រឿងញៀននោះទេ បើមានគឺមានតែអ្នកទៅកាប់ដំឡូងប៉ុណ្ណោះ។ ហើយពេលដល់ខែធ្វើស្រែ ក៏ឃើញឈ្មោះ [redacted] ឡា ធ្វើស្រែ និងដល់ខែដំឡូងក៏ធ្វើដំឡូង ចិញ្ចឹមមាន់តិចតួច ប៉ុណ្ណោះឯង។ ការរស់នៅក្នុងភូមិ ខ្លួនក៏មិនដែលលឺថាមានអ្នកណាពាក់ព័ន្ធនឹងគ្រឿងញៀនដែរ។ ចម្លើយខ្លួនមានតែប៉ុណ្ណឹងឯង ហើយក៏ជាចម្លើយពិតដែរ ខ្លួនហ៊ានទទួលខុសត្រូវចំពោះចម្លើយរបស់ខ្លួន។

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា ដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា៖ ខ្លួនចេះរកស៊ីលក់ថ្នាំញៀនប្រភេទម៉ាទឹកកក និងប្រភេទគ្រាប់អស់រយៈពេលជាងកន្លះឆ្នាំមកហើយ ដោយថ្នាំញៀនដែលខ្លួនលក់ គឺទិញពីឈ្មោះ ធី ប្រើប្រាស់លេខទូរស័ព្ទ [redacted]។ ហើយកាលពីម្សិលមិញ ខ្លួនបានទាក់ទងទៅឈ្មោះ វី ឱ្យផ្ញើថ្នាំញៀនមកឱ្យខ្លួន ហើយខ្លួនក៏ទទួលថ្នាំញៀននោះ គិតជាប្រាក់តម្លៃ ៥០០,០០០ រៀល



[redacted]

Scanned with CamScanner

ហើយក៏យកមកលាក់ទុកក្នុងរាវ  ក្រោយមកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង  ប៉ុន្តែនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ជនត្រូវចោទឈ្មោះ [redacted] ឡា បានឆ្លើយ ប្រហាក់ប្រហែលគ្នាថា៖  ខ្លួនសូមបដិសេធចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចកាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០២១ ទាំងអស់ព្រោះតែសមត្ថកិច្ចបានគំរាមខ្លួនយកចម្លើយ និងសូមបន្ថែមចម្លើយដូចខាងក្រោម៖ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០២១ វេលាម៉ោងប្រហែលជា ១១ ថ្ងៃ ពេលខ្លួន កំពុងតែបោសសំអាតផ្ទះរបស់ខ្លួន ក៏ស្រាប់តែមានសមត្ថកិច្ច បានមកឃាត់ខ្លួនយកមកសួរ នៅប៉ុស្តិ៍នគរបាល រដ្ឋបាលគោករមៀត ពាក់ព័ន្ធនិង ករណី ជួញដូរគ្រឿងញៀន ព្រោះតែសមត្ថកិច្ចបាន រកឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់ដែលលាក់ទុកនៅក្នុង ខោអាវរបស់ខ្លួន ដែលយកទៅឱ្យគេបោកគក់។ ខ្លួនមិនដឹងហេតុអ្វីបានជានៅក្នុងខោអាវដែលខ្លួនឱ្យគេបោកគក់នោះ មានបង្កប់គ្រឿងញៀននៅក្នុងនោះទេ ។ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០២១ វេលាម៉ោង ០៨ ព្រឹក ពេលខ្លួនកំពុងតែនៅផ្ទះ ក៏មានប្តីរបស់ឈ្មោះ [redacted] សួង ដែលរកស៊ីបោកខោអាវនៅតាមភូមិ បានមកប្រមូលខោអាវរបស់ខ្លួន និងប្រពន្ធ របស់ខ្លួនយកទៅបោកនៅផ្ទះរបស់ឈ្មោះ [redacted] សួង ដែលស្ថិតនៅក្បែរផ្សារបឹងត្រកួន ហើយក្រោយមកក៏ មានសមត្ថកិច្ចបានមកឃាត់ខ្លួន ពាក់ព័ន្ធនិងករណីរកឃើញគ្រឿងញៀនដែលលាក់ទុកនៅក្នុងខោអាវ ដែលខ្លួនយក ទៅឱ្យគេបោកចំនួន ០១ កញ្ចប់។ ចំពោះមូលហេតុខ្លួន និងប្រពន្ធជូលឈ្មោះ [redacted] សួង ឱ្យជួយបោកខោអាវឱ្យនោះ ដោយសារតែខ្លួន មានការរវល់និងការងារ ចំណែកឯប្រពន្ធរបស់ខ្លួនក៏កំពុងតែមានជំងឺផងដែរ ទើបគ្មាននរណាជាអ្នកបោកខោអាវ នោះទេ ហើយណាមួយឈ្មោះ [redacted] សួង ធ្លាប់មកយកខោអាវរបស់ខ្លួនយកទៅបោកគក់ប្រហែលជា ០៤ ទៅ ០៥ ដងមកហើយ។ ខ្លួនធ្លាប់មានជម្លោះជាមួយប្អូនស្រីរបស់ [redacted] សួង ឈ្មោះ [redacted] ស៊ីង ពាក់ព័ន្ធនិងករណី ខ្ចីប្រាក់ដោយខ្លួនធ្លាប់ខ្ចីប្រាក់ពីឈ្មោះ [redacted] ស៊ីង ហើយសងទៅវិញមានភាពយឺតយ៉ាវ ទើបបណ្តាលឱ្យឈ្លោះគ្នា តែម្តង។ គ្រឿងញៀនដែលសមត្ថកិច្ចបានរកឃើញនៅក្នុងខោអាវរបស់ខ្លួនយកទៅឱ្យឈ្មោះ [redacted] សួង បោកគក់នោះ គឺមិនមែនជារបស់ខ្លួននោះទេ។ ចំពោះគ្រឿងញៀនដែលសមត្ថកិច្ចថាជារបស់ខ្លួននោះ គឺមិនមែន ដកហូតពីលើខ្លួននោះទេ។ ចំពោះឈ្មោះ រី និងឈ្មោះ ធី ដែលខ្លួនបានឆ្លើយប្រាប់ថា ជាអ្នកលក់គ្រឿងញៀន ឱ្យខ្លួននោះ គឺខ្លួនមិនស្គាល់អ្នកទាំង ០២ នេះនោះទេ។ ហើយចំពោះគ្រឿងញៀនចំនួន ០១ គ្រាប់ ពណ៌ក្រហម ប្រភេទគ្រាប់មានអក្សរ WY ដែលសមត្ថកិច្ចរកឃើញនៅក្បែរបង្អួចផ្ទះរបស់ខ្លួននោះ គឺខ្លួនទិញទុកសម្រាប់ ប្រើប្រាស់ប៉ុណ្ណោះ។ ខ្លួនបច្ចុប្បន្នមានមុខរបរចិញ្ចឹមមាន់ ចិញ្ចឹមទា និងមានចម្ការដាំដំឡូងទំហំជិត ៥០ហិចតា ស្ថិតនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ដោយរកចំណូលបានប្រហែល ០៥ ទៅ ០៦ លានរៀល ក្នុងមួយខែ ហើយចំណាយក្នុងមួយខែអស់ប្រហែលជា ០៣ លានរៀល។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀន ប្រភេទគ្រាប់ ពណ៌ក្រហម ហើយក្នុងមួយសប្តាហ៍ខ្លួន ប្រើប្រាស់អស់ប្រហែលជា ០២ គ្រាប់ តម្លៃ ២០,០០០ រៀល ដោយទិញពីឈ្មោះ មុំ ភេទស្រី អាយុប្រហែលជាង ៤០ឆ្នាំ រស់នៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ខ្លួនមិនដឹងថាគ្រឿងញៀនដែលដកហូតពីកន្លែងបោកអ៊ុតនោះជាអ្នករបស់អ្នកណានោះទេ ហើយក៏មិនដឹងថាកន្លែងបោកអ៊ុតនោះរកស៊ីថ្នាំញៀនដែរឬអត់នោះទេ។ ខ្លួនស្នើសុំតំណាងអយ្យការអនុញ្ញាតឱ្យខ្លួនត្រឡប់ទៅផ្ទះវិញ និងជួយរកយុត្តិធម៌ឱ្យរូបខ្លួនផង ព្រោះខ្លួនមិន



[redacted]

បានប្រព្រឹត្តដូចការ ចោទប្រកាន់របស់គេឡើយ ហើយរឿងទៀតគ្រឿងញៀនដែលឆែកហូតបានពីកន្លែងបោកខោអាវ ក៏មិនមែនជារបស់ខ្លួនដែរ ព្រោះខោអាវរបស់ខ្លួន គេអ្នកស៊ីឈ្នួលបោកអ៊ុតយកទៅនោះ គឺមិនតិចប៉ុន្មាននោះទេ ហើយបានបែរជាមកចោទថាជារបស់ខ្លួនទៅវិញ។

-របាយការណ៍លេខ៖ ១៤៨/២១ ការិ.បគញ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ។

-មានការសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលើឈ្មោះ [redacted] ឡា លេខ៖ ២៥១ ព្រព.II(ខ)/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-មានការបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] ហៅ ម៉ុំ លេខ៖ ៣៤ ព្រព.II(ខ)/២១ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-មានការចាត់ឱ្យស្រាវជ្រាវអត្តសញ្ញាណលើឈ្មោះ ធី និងឈ្មោះ វី លេខ៖ ៦៨១ពស.ព្រស (ខ)/២១ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។

-ឯកសារមួយចំនួន ដែលទាក់ទិនទៅនឹងសំណុំរឿងនេះ។

**យល់ឃើញថា៖**

-របាយការណ៍លេខ៖ ១៤៨/២១ ការិ.បគញ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា កាលពីថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០២១ មានប្រជាពលរដ្ឋឈ្មោះ [redacted] ហួរ បានរាយការណ៍មកកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលគោករមៀត នៃអធិការដ្ឋាននគរបាលស្រុកថ្មពួក មកថាមានឈ្មោះ [redacted] ឡា បានយកខោអាវមកបោកអ៊ុតដូចសព្វដង នៅចំណុចភូមិត្រពាំងសំរោង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ លុះពេលយកខោអាវទៅដាក់ក្នុងម៉ាស៊ីនបោកអ៊ុត ស្រាប់តែឃើញថង់មួយនៅក្រោមខោអាវ ហើយឈ្មោះ [redacted] ហួរ បានស្រាយថង់បើកមើលថង់ពណ៌ខ្មៅ ស្រាប់តែឃើញថ្នាំញៀនប្រភេទម្សៅក្រាម ពណ៌ ស ថ្លា ចំនួន ០១ កូនថង់ និងថង់ប្លាស្ទិកមួយចំនួន ហើយក្រោយពីទទួលព័ត៌មាន កម្លាំងយើងបានចុះទៅឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ឡា ព្រមទាំងឆែកឆេររកឃើញវត្ថុតាង ថ្នាំគ្រាប់ពណ៌ក្រហមមានអក្សរ WY ចំនួន ០១ គ្រាប់ ច្រកក្នុងថង់បោះចោលក្បែរបង្អួច និងទូរស័ព្ទដៃ ចំនួន ០១ គ្រឿង។

-ចម្លើយបដិសេធរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា ដែលបានឆ្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ថា ខ្លួនមិនបានរកស៊ីលក់គ្រឿងញៀនទេនោះ គឺគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ដោយសារតែនៅដំណាក់កាលនគរបាលយុត្តិធម៌ ឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថា ខ្លួនរកស៊ីលក់ថ្នាំញៀនអស់រយៈពេល ០៦ ខែមកហើយ ដោយទិញពីឈ្មោះ វី និងឈ្មោះ ធី ហើយជាក់ស្ដែងឈ្មោះ [redacted] ឡា



[redacted]

ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ វី ចំនួន ៥០០,០០០ រៀល យកមកលក់បន្តផងដែរ ហើយម្យ៉ាងទៀតនៅពេលដែលសមត្ថកិច្ចចុះទៅឃាត់ខ្លួនឈ្មោះ [redacted] ឡា នោះ សមត្ថកិច្ចក៏បានបានរកឃើញគ្រឿងញៀនប្រភេទថ្នាំគ្រាប់ពណ៌ក្រហម អក្សរ WY ចំនួន ០១ គ្រាប់នៅក្បែរផ្ទះរបស់ឈ្មោះ [redacted] ឡា ផងដែរ។

-ផ្អែកតាមឯកសារភស្តុតាងផ្សេងៗ បញ្ជាក់បានថា ជនត្រូវចោទឈ្មោះ [redacted] ឡា ពិតជាបានប្រព្រឹត្តបទល្មើសជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

-ផ្អែកតាមចម្លើយបំភ្លឺរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា បញ្ជាក់បានថា ជនត្រូវចោទឈ្មោះ [redacted] មុំ ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា ស្តែងឡើងដោយចេតនាទុច្ចរិត ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះត្រូវបានច្បាប់បញ្ញត្តិយ៉ាងតឹងរឹងចំពោះជន ដែលប្រព្រឹត្តអំពើនេះធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ និងសណ្តាប់ធ្នាប់សង្គម ហើយត្រូវបានច្បាប់បញ្ញត្តិថា ជាបទល្មើសព្រហ្មទណ្ឌ។

-អំពើប្រព្រឹត្តរបស់ជនត្រូវចោទឈ្មោះ [redacted] មុំ ស្តែងឡើងដោយចេតនាទុច្ចរិត ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះត្រូវបានច្បាប់បញ្ញត្តិយ៉ាងតឹងរឹងចំពោះជន ដែលប្រព្រឹត្តអំពើនេះធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ និងសណ្តាប់ធ្នាប់សង្គម ហើយត្រូវបានច្បាប់បញ្ញត្តិថា ជាបទល្មើសព្រហ្មទណ្ឌ។

-ជនត្រូវចោទឈ្មោះ [redacted] ឡា ជាមនុស្សមានស្មារតីល្អ យល់ដឹងនូវអំពើប្រព្រឹត្តរបស់ខ្លួន ហើយមានចេតនាចង់ឲ្យអំពើល្មើសខាងលើកើតមាន។

-ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ បានចេញដីកាចាត់ឱ្យស្រាវជ្រាវរត្តសញ្ញាណលើឈ្មោះ ធី និងឈ្មោះ វី លេខ៖ ៦៨១ពស.ព្រស (ច)/២១ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០២១ ប៉ុន្តែគ្មានលទ្ធផលគប្បីលើកលែងការចោទប្រកាន់។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើ៖ ឈ្មោះ [redacted] មុំ ហៅ មុំ ភេទស្រី កើតថ្ងៃទី ០៩.០៦.១៩៦៨ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើ៖ ឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ ១៩៨៣ ពីបទ៖**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។



[redacted]

Scanned with CamScanner

4

# ហេតុដូច្នេះសម្រេច

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរ៖

ក.លើកលែងការចោទប្រកាន់៖

១-ឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា ៤២ឆ្នាំ (អត្តសញ្ញាណមិនគ្រប់គ្រាន់)

២-ឈ្មោះ រី ភេទប្រុស អាយុប្រហែលជា ៣២ឆ្នាំ (អត្តសញ្ញាណមិនគ្រប់គ្រាន់)

ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

ខ.សម្រេចបញ្ជូនជនត្រូវចោទ៖

៣-ឈ្មោះ [redacted]មុំ ហៅ មុំ ភេទស្រី កើតថ្ងៃទី ០៩.០៦.១៩៦៨ (គេចខ្លួន)

*ទៅជំនុំជម្រះ* ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោះ [redacted]ឡា ភេទប្រុស កើតឆ្នាំ ១៩៨៣ (មានខ្លួន)

*ទៅជំនុំជម្រះ* ពីបទ៖ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ មានចែងតាមបញ្ញត្តមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

ថ្ងៃ.សុក្រ...៨...រោច.. ខែ....ពិសាខ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

បន្ទាយមានជ័យ ថ្ងៃទី...០៤... ខែ.មិថុនា. ឆ្នាំ២០២១

**តំណាងអយ្យការ**

[redacted]



[redacted]

Scanned with CamScanner